**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះវិហារ**

- សំណុំរឿងរដ្ឋប្បវេណីលេខ: ៦៧
ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១
- សាលក្រមរដ្ឋប្បវេណីលេខ: ០៤(ក)
ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រះវិហារ

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនៅថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២២ ដោយមានសមាសភាពចូលរួមដូចតទៅៈ

**ចៅក្រម**

ឯកឧត្តម [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះវិហារ

**ដើមចោទ:**

-ឈ្មោះ [redacted] ចន្ទ ភេទស្រី អាយុ ៤៦ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើត [redacted] និងទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] កន (រស់) ម្ដាយឈ្មោះ [redacted] រី (រស់) ប្ដីឈ្មោះ [redacted] គារិទ្ធិ មានកូនចំនួន ២នាក់ ។

**ចុងចម្លើយ:**

-ឈ្មោះ [redacted] ធូ ភេទស្រី អាយុ ៤១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] ។

## <u>អង្គហេតុ និងចំណុចវិវាទ</u>

ក- ការទាមទាររបស់ដើមចោទ:

ដើមចោទប្ដឹងសុំឲ្យតុលាការចេញសាលក្រម:

- ទី១ បង្គាប់ឲ្យឈ្មោះ [redacted] ធូ ភេទស្រី អាយុ ៤១ឆ្នាំ សងប្រាក់ចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល ។
- ទី២ សុំទាមទារសំណងជម្ងឺចិត្ត ការខូចខាតពេលវេលា និងការចំណាយផ្សេងៗសរុបចំនួន ៤.០០០.០០០ (បួនលាន) រៀល ។
-ទី៣ ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

ខ- ការពន្យល់ត្រួសៗ អំពីរឿងក្តី:

កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២០ ឈ្មោះ [redacted] ធូ ភេទស្រី អាយុ ៩១ឆ្នាំ បានខ្ចីប្រាក់ពីឈ្មោះ [redacted] ចាន់នៀត ភេទស្រី អាយុ ៣១ឆ្នាំ ចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល ដោយសន្យាសងប្រាក់ ត្រឹមថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ដោយពុំមានដាក់របស់បញ្ចាំអ្វីឡើយ តែបានធ្វើកិច្ចសន្យាខ្ចីប្រាក់ត្រឹមត្រូវតាមច្បាប់ ដោយមានឈ្មោះ [redacted] ចន្ទូ ភេទស្រី អាយុ ៤៦ឆ្នាំ ជាអ្នកធានាឲ្យឈ្មោះ [redacted] ធូ ហើយដោយពុំមានគិតការប្រាក់ ។ ចាប់តាំងពីឈ្មោះ [redacted] ធូ បានខ្ចីប្រាក់មក បែរជាឈ្មោះ [redacted] ធូ គេចវេសមិនព្រមសង ហើយបែរជានិយាយថាគ្មានប្រាក់សងមកឲ្យឈ្មោះ [redacted] ចន្ទូ ទៅវិញ ទើបឈ្មោះ [redacted] ចន្ទូ ទាមទារប្រាក់ពីឈ្មោះ [redacted] ធូ ដើម្បីបានប្រាក់ទុកសងទៅឈ្មោះ [redacted] ចាន់នៀត វិញ ។

គ- ការអះអាងរបស់ភាគី៖ (ចុងចម្លើយឈ្មោះ [redacted] ធូ ភេទស្រី អាយុ ៩១ឆ្នាំ អវត្តមាននាកាលបរិច្ឆេទធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់) ។

**ការអះអាងរបស់ដើមចោទ:**

- ឈ្មោះ [redacted] ចន្ទូ បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២០ ឈ្មោះ [redacted] ធូ ភេទស្រី បានខ្ចីប្រាក់ពីឈ្មោះ [redacted] **ចាន់នៀត** ភេទស្រី ចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល ដោយសន្យាសងប្រាក់ ត្រឹមថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ដោយពុំមានដាក់របស់បញ្ចាំអ្វីឡើយ តែបានធ្វើកិច្ចសន្យាខ្ចីប្រាក់ត្រឹមត្រូវតាមច្បាប់ ដោយមានខ្លួនជាអ្នកធានាឲ្យចុងចម្លើយ ហើយដោយពុំមានគិតការប្រាក់ ។ ចាប់តាំងពីចុងចម្លើយ បានខ្ចីប្រាក់មក បែរជាចុងម្លើយនេះគេចវេសមិនព្រមសង ហើយបែរជានិយាយថាគ្មានប្រាក់សងមកឲ្យខ្លួនទៅវិញ ទើបខ្លួនទាមទារប្រាក់ពីចុងចម្លើយ ដើម្បីបានប្រាក់ទុកសងទៅឈ្មោះ [redacted] **ចាន់នៀត** វិញ ។ ហេតុដូច្នេះ ខ្លួនសុំឲ្យចុងចម្លើយឈ្មោះ [redacted] ធូ សងប្រាក់ចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល មកឲ្យខ្លួន គ្រប់ចំនួន វិញ សុំទាមទារសំណងជម្ងឺចិត្ត ការខូចខាតពេលវេលា និងការចំណាយផ្សេងៗសរុបចំនួន ៤.០០០.០០០ (បួនលាន) រៀល និងសុំឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

-លោកមេធាវី [redacted] អ្នកតំណាងដោយអាណត្តិឲ្យដើមចោទថ្លែងការណ៍ថា: កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២០ ឈ្មោះ [redacted] ធូ ភេទស្រី បានខ្ចីប្រាក់ពីឈ្មោះ [redacted] **ចាន់នៀត** ចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល ដោយសន្យាសងប្រាក់ ត្រឹមថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ដោយពុំមានដាក់របស់បញ្ចាំអ្វីឡើយ តែបានធ្វើកិច្ចសន្យាខ្ចីប្រាក់ត្រឹមត្រូវតាមច្បាប់ ដោយមានកូនក្តីខ្លួនឈ្មោះ [redacted] ចន្ទូ ជាអ្នកធានាឲ្យចុងចម្លើយ ហើយដោយពុំមានគិតការប្រាក់ ។ ចាប់តាំងពីចុងចម្លើយ បានខ្ចីប្រាក់មក បែរជាចុងម្លើយ នេះគេចវេសមិនព្រមសង ហើយបែរជានិយាយថាគ្មានប្រាក់សងមកឲ្យកូនក្តីខ្លួនទៅវិញ ។ ទើបកូនក្តីខ្លួនទាមទារប្រាក់ពីចុងចម្លើយ ដើម្បីបានប្រាក់ទុកសងទៅឈ្មោះ [redacted] ចាន់នៀត វិញ ។ ហេតុដូច្នេះ ខ្លួនសុំឲ្យចុងចម្លើយឈ្មោះ [redacted] ធូ សងប្រាក់ចំនួន ១៦.

០០០.០០០ (ដប់ប្រាំមួយលាន) រៀល មកឲ្យកូនក្តីខ្លួនឈ្មោះ [redacted] ចន្ធូ គ្រប់ចំនួន វិញ សុំទាមទារសំណងជម្ងឺចិត្ត ការខូចខាតពេលវេលា និងការចំណាយផ្សេងៗសរុបចំនួន ៤.០០០.០០០ (បួនលាន) រៀល និងសុំឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

ឃ- ចំណុចវិវាទ: គ្មាន (ដោយសារចុងចម្លើយឈ្មោះ [redacted] ធូ ភេទស្រី អាយុ ៤១ឆ្នាំ អវត្តមាន)

**សំអាងហេតុ**

ឆ្លងតាមលទ្ធផលសាកសួរ និងពិនិត្យភស្តុតាងនៅនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

១- កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២០ ឈ្មោះ [redacted] ធូ ភេទស្រី អាយុ ៤១ឆ្នាំ បានខ្ចីប្រាក់ពីឈ្មោះ [redacted] ចាន់នៀត ភេទស្រី អាយុ ៣១ឆ្នាំ ចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល ដោយសន្យាសងប្រាក់ ត្រឹមថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ដោយពុំមានដាក់របស់បញ្ចាំអ្វីឡើយ តែបានធ្វើកិច្ចសន្យាខ្ចីប្រាក់ត្រឹមត្រូវតាមច្បាប់ ដោយមាន [redacted] ចន្ធូ ជាអ្នកធានាឲ្យឈ្មោះ [redacted] ធូ ហើយដោយពុំមានគិតការប្រាក់ ចាប់តាំងពីឈ្មោះ [redacted] ធូ បានខ្ចីប្រាក់មក បែរជាឈ្មោះ [redacted] ធូ គេចវេសមិនព្រមសងប្រាក់ ហើយបែរជានិយាយថាគ្មានប្រាក់សងមកឲ្យឈ្មោះ [redacted] ចន្ធូ ទៅវិញ ។ ទើបឈ្មោះ [redacted] ចន្ធូ ទាមទារប្រាក់ពីឈ្មោះ [redacted] ធូ បានប្រាក់ទុកសងទៅឈ្មោះ [redacted] ចាន់នៀត វិញ

២- ឈ្មោះ [redacted] ចន្ធូ បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២០ ឈ្មោះ [redacted] ធូ ភេទស្រី បានខ្ចីប្រាក់ពីឈ្មោះ [redacted] ចាន់នៀត ភេទស្រី ចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល ដោយសន្យាសងប្រាក់ ត្រឹមថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ដោយពុំមានដាក់របស់បញ្ចាំអ្វីឡើយ តែបានធ្វើកិច្ចសន្យាខ្ចីប្រាក់ត្រឹមត្រូវតាមច្បាប់ ដោយមានខ្លួនជាអ្នកធានាឲ្យចុងចម្លើយ ហើយដោយពុំមានគិតការប្រាក់ ។ ចាប់តាំងពីចុងចម្លើយ បានខ្ចីប្រាក់មក បែរជាចុងចម្លើយនេះគេចវេសមិនព្រមសងប្រាក់ ហើយបែរជានិយាយថាគ្មានប្រាក់សងមកឲ្យខ្លួនទៅវិញ ។ ទើបខ្លួនទាមទារប្រាក់ពីចុងចម្លើយ ដើម្បីបានប្រាក់ទុកសងទៅឈ្មោះ [redacted] ចាន់នៀត វិញ ។ ហេតុដូច្នេះ ខ្លួនសុំឲ្យចុងចម្លើយឈ្មោះ [redacted] ធូ ភេទស្រី សងប្រាក់ចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល ឲ្យមកខ្លួន គ្រប់ចំនួន វិញ សុំទាមទារសំណងជម្ងឺចិត្ត ការខូចខាតពេលវេលា និងការចំណាយផ្សេងៗសរុបចំនួន ៤.០០០.០០០ (បួនលាន) រៀល និងសុំឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

៣- លោកមេធាវី [redacted] អ្នកតំណាងដោយអាណត្តិឲ្យដើមចោទថ្លែងការណ៍ថា: កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២០ ឈ្មោះ [redacted] ធូ ភេទស្រី អាយុ ៤១ឆ្នាំ បានខ្ចីប្រាក់ពីឈ្មោះ [redacted] ចាន់នៀត ភេទស្រី អាយុ អាយុ ៣១ឆ្នាំ ចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល ដោយសន្យាសងប្រាក់ ត្រឹមថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ដោយពុំមានដាក់របស់បញ្ចាំអ្វីឡើយ តែបានធ្វើកិច្ចសន្យាខ្ចីប្រាក់ត្រឹមត្រូវតាមច្បាប់ ដោយមានកូនក្តីខ្លួនជាអ្នកធានាឲ្យចុងចម្លើយ ហើយដោយពុំមានគិតការប្រាក់ ។



Scanned with CamScanner

ចាប់តាំងពីចុងចម្លើយ បានខ្ចីប្រាក់មក បែរជាចុងចម្លើយនេះគេចវេសមិនព្រមសង ហើយបែរជានិយាយថាគ្មានប្រាក់សងមកឲ្យកូនក្តីខ្លួនទៅវិញ ។ ទើបកូនក្តីខ្លួនទាមទារប្រាក់ពីចុងចម្លើយ ដើម្បីបានប្រាក់ទុកសងទៅឈ្មោះ [redacted] ចាន់នឿត ភេទស្រី វិញ ។ ហេតុដូច្នេះ ខ្លួនសុំឲ្យចុងចម្លើយឈ្មោះ [redacted] ធូ ភេទស្រី អាយុ ៤១ឆ្នាំ សងប្រាក់ចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល មកឲ្យកូនក្តីខ្លួនឈ្មោះ [redacted] ចន្ទ ភេទស្រី គ្រប់ចំនួន វិញ សុំទាមទារសំណងជម្ងឺចិត្ត ការខូចខាតពេលវេលា និងការចំណាយផ្សេងៗសរុបចំនួន ៤.០០០.០០០ (បួនលាន) រៀល និងសុំឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

៤- តុលាការបានពិនិត្យភស្តុតាងដែលដើមចោទបានដាក់ជូនជាឯកសារដូចជា លិខិតខ្ចីប្រាក់ដោយបង់ការប្រាក់រាល់ថ្ងៃ ថ្ងៃទី១២ ខែមករា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] ធូ ភេទស្រី ចំនួន ១ (មួយ) សន្លឹក (ច្បាប់ថតចម្លង) , អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ 062097540 ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ ២០១៦ របស់ឈ្មោះ [redacted] ធូ ភេទស្រី ចំនួន ១ (មួយ) សន្លឹក (ច្បាប់ថតចម្លង) និងលិខិតប្រគល់សិទ្ធិ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ចាន់នឿត ភេទស្រី និងឈ្មោះ [redacted] ចន្ទ ភេទស្រី ចំនួន ១ (មួយ) សន្លឹក ។

៥- ដើមចោទទាមទារសុំឲ្យចុងចម្លើយសងប្រាក់ ចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល ដោយពុំគិតការប្រាក់ឡើយ ដោយផ្អែកលើ លិខិតខ្ចីប្រាក់ដោយបង់ការប្រាក់រាល់ថ្ងៃ ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] ធូ ភេទស្រី ចំនួន ១ (មួយ) សន្លឹក (ច្បាប់ថតចម្លង) ពិតប្រាកដមែន គប្បីតុលាការពិចារណា និងសម្រេច ។

៦- ដើមចោទទាមទារឲ្យចុងចម្លើយសងសំណងជម្ងឺចិត្ត ការខូចខាតពេលវេលា និងការចំណាយផ្សេងៗសរុបចំនួន ៤.០០០.០០០ (បួនលាន) រៀល គប្បីតុលាការសម្រេចឲ្យចុងចម្លើយសងសំណងជម្ងឺចិត្ត ការខូចខាតពេលវេលា និងការចំណាយផ្សេងៗលើប្រាក់ដែលមិនបានសង តាមមាត្រា ៣៩៨ នៃក្រមរដ្ឋប្បវេណី ។

៧- តុលាការបានធ្វើការបញ្ជូនដីកាកោះហៅចុងចម្លើយឈ្មោះ [redacted] ធូ ភេទស្រី តាមរយៈចៅសង្កាត់ប៉ាលហាល ហើយឈ្មោះ [redacted] បាន ភេទប្រុស (ត្រូវជាប្តី) របស់ចុងចម្លើយបានទទួលដីកាកោះហៅ ត្រឹមត្រូវតាមនីតិវិធី ប៉ុន្តែចុងចម្លើយឈ្មោះ [redacted] ធូ ភេទស្រី មិនបានចូលរួមរាល់នីតិវិធី ដូច្នេះតុលាការត្រូវចាត់ទុកថាចុងចម្លើយទទួលស្គាល់ការទាមទារតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ដែលទាក់ទងនឹងអង្គហេតុ ហើយដោយការទាមទាររបស់ដើមចោទមានលក្ខណៈត្រឹមត្រូវ តុលាការត្រូវទទួលស្គាល់ការទាមទាររបស់ដើមចោទ និងសម្រេចប្រកាសសាលក្រមដោយកំបាំងមុខចុងចម្លើយ តាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៨- ប្រាក់ប្រដាប់ គប្បីជាបន្ទុករបស់អ្នកចាញ់ក្តី តាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។



Scanned with CamScanner

## សេចក្ដីសម្រេចបញ្ចប់

១. បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ធូ ភេទស្រី អាយុ ៥១ឆ្នាំ សងប្រាក់មកដើមចោទឈ្មោះ [redacted] ចន្ទ ភេទស្រី អាយុ ៥៦ឆ្នាំ តាមសំណងដូចខាងក្រោម៖

ក. សងប្រាក់ចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល ។

ខ. សងសំណងជម្ងឺចិត្ត ការខូចខាតពេលវេលា និងការចំណាយផ្សេងៗសរុបចំនួន ៤.០០០.០០០ (បួនលាន) រៀល ។

២. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ចំពោះមុខដើមចោទ និងអ្នកតំណាងដោយអាណត្តិឲ្យដើមចោទ, កំបាំងមុខចុងចម្លើយ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ។

បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា ឯកឧត្តម [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ១៤កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ព្រះវិហារ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]